International Network for Economic, Social & Cultural Rights
Red Internacional para los Derechos Económicos, Sociales y Culturales
Réseau international pour les droits économiques, sociaux et culturels
الشبكة العالمية للحقوق الاقتصادية و الاجتماعية و الثقافية

ចេញផ្សាយជាបន្ទាន់

# អង្គការអន្តរជាតិជាច្រើនអំពាវនាវ សូមឲ្យបញ្ឈប់ការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សដោយមិនត្រឹមត្រូវនៅកម្ពុជា

ទីក្រុងញូវយ៉ក ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤៖ បណ្ដាញអន្តរជាតិសម្រាប់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ESCR-Net) បានផ្ញើលិខិតមួយច្បាប់ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ ទៅកាន់សម្ដេចនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ដើម្បីបង្ហាញការព្រួយបារម្ភជាខ្លាំងទៅលើការចាប់ខ្លួន និងការផ្ដន្ទាទោសថ្មីៗនេះមកលើសកម្មជនសិទ្ធិដីធ្លីជាស្ត្រីចំនួន ៧នាក់ ដែលបានព្យាយាមការពារសិទ្ធិមនុស្ស និងសិទ្ធិរបស់ក្រុមគ្រួសារនានាដែលរស់នៅក្នុងតំបន់បឹងកក់ ដែលជាតំបន់ដ៏ធំមួយនៅក្នុងរាជធានីភ្នំពេញនៃប្រទេសកម្ពុជា។

ស្ត្រីទាំងនោះ ត្រូវបានគេរាយការណ៍ថាត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១០ ខែវិច្ឆិកា នៅពេលដែលកំពុងតវ៉ាសូមឲ្យមានការចាប់អារម្មណ៍ លើទឹកជន់លិចនៅក្នុងតំបន់របស់អ្នកទាំងនោះកាលពីខែថ្មីៗកន្លងទៅ។ ក្រោយមកនាថ្ងៃដដែល ជនជាប់ចោទទាំង ៧នាក់ ត្រូវបានជំនុំជម្រះ និងផ្ដន្ទាទោសនូវទោសជាប់ពន្ធនាគារអតិបរមាដល់ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ ២លានរៀលក្នុងម្នាក់ៗ។

នៅថ្ងៃបន្ទាប់ អ្នកការពារសិទ្ធិមនុស្សចំនួន ៩នាក់ផ្សេងទៀត ត្រូវបានឃុំខ្លួនបន្តបន្ទាប់នៅខណ:ដែលកំពុងតវ៉ាអហិង្សានៅក្រៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីអំពាវនាវសូមឲ្យមានការដោះលែងស្ត្រីទាំង ៧នាក់។ នៅថ្ងៃបន្ទាប់ ជនជាប់ចោទនីមួយៗ ត្រូវបានផ្ដន្ទាទោសជាប់ពន្ធនាគារ ១ឆ្នាំ។ នៅពេលដែលមានប្រជាពលរដ្ឋជាច្រើនប្រមូលផ្ដុំគ្នាតវ៉ាការចាប់ស្ត្រីជាអ្នកការពារសិទ្ធិមនុស្សទាំងនោះដាក់ពន្ធនាគារ អ្នកទាំងនោះក៏ត្រូវបានឃុំខ្លួនផងដែរ។ បច្ចុប្បន្ននេះជាសរុប មនុស្សចំនួន ១៩ នាក់ ត្រូវបានឃុំខ្លួន។

សកម្មជនសិទ្ធិមនុស្ស និងពលរដ្ឋជាច្រើន បានបន្ទោសការលិចលង់ មកពីការចាក់បំពេញផ្ទៃបឹង បន្ទាប់ពីទឹកបឹងត្រូវបានបូមចេញដើម្បីយកដីធ្វើអាជីវកម្មអភិវឌ្ឍវិស័យអចលនវត្ថុ ដែលត្រូវបានធ្វើឡើងដោយក្រុមហ៊ុន ស៊ូកាគូ អ៊ីន ជាក្រុមហ៊ុនសាងសង់របស់សមាជិក

ព្រឹទ្ធសភា លោក ឡៅ ម៉េងឃីន។

អ្នកតវ៉ាជាច្រើន អះអាងថាបន្ទាប់ពីត្រូវបានបណ្តេញចេញដោយបង្ខំប្រជាពលរដ្ឋជិត ២០.០០០ នាក់ ពីតំបន់នោះ ដោយសាលារាជធានីភ្នំពេញនៅឆ្នាំ ២០០៨ ទឹកជំនន់យ៉ាងអាក្រក់នៅជុំវិញសហគមន៍ បានធ្វើឲ្យមានផលប៉ះពាល់យ៉ាងច្រើនដល់សុខភាព ផ្ទះសម្បែង និងមុខរបររបស់គ្រួសារអ្នកទាំងនោះ។

លិខិតមួយច្បាប់នេះ ដែលត្រូវបានគាំទ្រដោយអង្គការចំនួនជាង ២២០ និងបុគ្គលចំនួនជាង ៥០ នាក់ នៅក្នុងប្រទេសចំនួន ២០ បានលើកឡើងនូវការព្រួយបារម្ភថា ការចាប់ខ្លួន ការចេញដីកាកោះហៅ និងការចោទប្រកាន់ គឺជាសកម្មភាពវាយតបវិញទៅលើអ្នកដែលចង់ការពារសិទ្ធិមនុស្ស ហើយសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា សូមបញ្ឈប់ការផ្តន្ទាទោសដែលមានលក្ខណៈនយោបាយទាំងអស់មកលើអ្នកការពារសិទ្ធិមនុស្សដែលកំពុងធ្វើការដើម្បីលើកកំពស់សិទ្ធិរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់បឹងកក់។

ESCR-Net ក៏សូមអំពាវនាវ សូមឲ្យមានការស៊ើបអង្កេតភ្លាមៗ ដោយឯករាជ្យ និងមានប្រសិទ្ធិភាព ទៅលើការរំលោភសិទ្ធិមនុស្សទាំងអស់ដែលពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំលើសហគមន៍បឹងកក់ រួមទាំងដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងទឹកជំនន់ ប្រព័ន្ធបង្ហូរទឹក ការផ្តល់សំណង និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅនឹងកន្លែង និងឆ្ងាយពីកន្លែង ដែលតាំងទីលំនៅ។

ជាចុងក្រោយ លិខិតនេះ សំនូមពរដល់រាជរដ្ឋាភិបាលកម្ពុជា សូមឲ្យអនុវត្តនៅការស៊ើបអង្កេតភ្លាមៗ ឯករាជ្យ និងមានប្រសិទ្ធិភាព ទៅលើការរំលោភសិទ្ធិមនុស្សទាំងអស់ដែលពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រុមហ៊ុន ស៊ូកាគូ អ៊ីន ហើយចាត់វិធានការណ៍សមរម្យ ដើម្បីធានាថាតាមរយៈប្រព័ន្ធតុលាការ រដ្ឋបាល និងច្បាប់ ឬមធ្យោបាយដទៃទៀត សហគមន៍ដែលរងផលប៉ះពាល់ពីការរំលោភសិទ្ធិមនុស្សពីក្រុមហ៊ុនទាំងនោះ ទទួលបានសំណងដ៏មានប្រសិទ្ធភាព។

លិខិតមួយច្បាប់ពេញ អាចយកបានតាមរយៈ៖ http://www.escr-net.org/node/365714

**អំពី ESCR-Net**

បណ្តាញអន្តរជាតិសម្រាប់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ESCR-Net) មានទំនាក់ទំនងជាមួយអង្គការ ចលនាសង្គម និងសកម្មជនជាង ២៧០ មកពី ៧០ប្រទេសទូទាំង

International Network for Economic, Social & Cultural Rights
Red Internacional para los Derechos Económicos, Sociales y Culturales
Réseau international pour les droits économiques, sociaux et culturels
الشبكة العالمية للحقوق الاقتصادية و الاجتماعية و الثقافية

ពិភពលោក ដែលផ្តល់នូវការផ្លាស់ប្តូរយុទ្ធសាស្រ្ត និងការតស៊ូមតិរួម ដើម្បីកសាងចលនាពិភពលោកមួយក្នុងការធ្វើឲ្យមានពិតនូវសិទ្ធិមនុស្ស និងយុត្តិធម៌សង្គមសម្រាប់ទាំងអស់គ្នា។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**


លោក អ៊ី សារ៉ុម (ភាសាអង់គ្លេស/ខ្មែរ)
នាយកប្រតិបត្តិ, សមាគមធាងត្នោត
sarom@teangtnaut.org

លោក អៀង វុទ្ធី (ភាសាអង់គ្លេស/ខ្មែរ)
នាយកប្រតិបត្តិ, អង្គការសមធម៌កម្ពុជា
vuthy@equitablecambodia.org

លោក Sergio Rozalén (ភាសាអង់គ្លេស/អេស្ប៉ាញ)
អ្នកសម្របសម្រួលផ្នែកទំនាក់ទំនង
srozalen@escr-net.org
www.escr-net.org